គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០៧២/១៦ ក.ស

# កំណត់ហេតុនៃកិច្ចប្រជុំ
# ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការ របស់គណៈកម្មការរួម កម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែឧសភា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងដប់ប្រាំរសៀល នៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគារ "A" មានបើកកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការរបស់គណៈកម្មការរួម កម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ពលរដ្ឋកម្ពុជាពីសហរដ្ឋអាមេរិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំរួមមានតំណាង ក្រសួងមហាផ្ទៃ ក្រសួងការបរទេស ទីប្រឹក្សារាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ។

ជាបឋម **សម្តេចក្រឡាហោម** បានមានប្រសាសន៍អំពីគោលបំណងនៃកិច្ចប្រជុំ គឺដើម្បីសម្រេចនូវគោលជំហររាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាពីសហរដ្ឋអាមេរិក និងធ្វើការពិនិត្យកែសម្រួលអនុស្សរណៈរវាងកម្ពុជា-សហរដ្ឋអាមេរិក ដើម្បីដោះស្រាយឲ្យបាននូវបញ្ហាដែលកើតមានឡើងក្នុងការអនុវត្តអនុស្សរណៈនាពេលកន្លងមក ។

យោងតាមគោលបំណងខាងលើនេះ អង្គប្រជុំបានប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖

**១. មូលហេតុដែលនាំឲ្យមានការពិនិត្យកែសម្រួលអនុស្សរណៈ**

(ដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ)

មូលហេតុដែលនាំឲ្យមានការជួបប្រជុំដើម្បីពិនិត្យកែសម្រួលអនុស្សរណៈនេះឡើងវិញ គឺដោយសារយើងបានទទួលលិខិតពី 1LOVE MOVEMENT សុំធ្វើការជួបពិភាក្សា ដោយមានភ្ជាប់ជាមួយលិខិតគាំទ្រពីរដ្ឋសភា ក្រុមប្រឹក្សា និងអភិបាលក្រុងមួយចំនួននៃសហរដ្ឋអាមេរិក បានឯកភាពការស្នើសុំពីប្រជាជននៅក្នុងសហគមន៍ជនភៀសខ្លួនកម្ពុជានៅសហរដ្ឋអាមេរិក សុំឲ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការកែសម្រួលនូវអនុស្សរណៈជាមួយសហរដ្ឋអាមេរិក ធ្វើយ៉ាងណាឲ្យការបញ្ជូនត្រឡប់ ឬការធ្វើមាតុភូមិនិវត្តន៍ ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តមិនមានការបង្ខិតបង្ខំ ព្រោះតាមរយៈការបញ្ជូនត្រឡប់កន្លងមកបានធ្វើដោយមានការបង្ខិតបង្ខំពីអាជ្ញាធរមានសមត្ថកិច្ចសហរដ្ឋអាមេរិក ។ បច្ចុប្បន្ន អាមេរិកកំពុងធ្វើការជាមួយសហគមន៍ជនជាតិអាស៊ីមានដូចជាខ្មែរ ឡាវ វៀតណាម ដែលបានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិកកាលពី ៤០ឆ្នាំមុន ចំនួន ១៥.០០០នាក់ ក្នុងនោះមានជនជាតិ

ខ្មែរ ៤.០០០នាក់ ហើយ ៦៥-៨៥ភាគរយនៃអ្នកទាំងនោះ កំពុងប្រឈមមុខនឹងការបញ្ជូនត្រឡប់មកប្រទេសកំណើត ដោយផ្អែកតាមច្បាប់អន្តោប្រវេសន៍អាមេរិក ចោទថាពួកគេប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។

**២. ប្រវត្តិនៃការចុះអនុស្សរណៈ**

(ដោយ ឯកឧត្តម **សៀង ឡាប្រេស្ស** ទីប្រឹក្សារាជរដ្ឋាភិបាល)

នៅក្នុងឆ្នាំ២០០០ ក្រសួងការបរទេសកម្ពុជាបានជួបប្រជុំជាមួយសហរដ្ឋអាមេរិជាច្រើនលើក ដែលកាលនោះសហរដ្ឋអាមេរិកចង់ដោះស្រាយ និងធ្វើមាតុភូមិនិវត្តន៍ជនល្មើសព្រហ្មទណ្ឌជាជនជាតិខ្មែរចំនួន ១៤១នាក់ ដែលកំពុងជាប់ឃុំនៅសហរដ្ឋអាមេរិក ឲ្យត្រឡប់មកកម្ពុជាវិញ ។ ពេលនោះកម្ពុជាបានបដិសេធទទួលយកជនល្មើសព្រហ្មទណ្ឌទាំងនោះ ដោយមូលហេតុថា "ពួកគេបានរស់នៅទីនោះ មានសញ្ជាតិអាមេរិក ប្រព្រឹត្តបទល្មើសនៅទីនោះ ដូចនេះជាការទទួលខុសត្រូវរបស់អាមេរិក" តែចំពោះករណីពលរដ្ឋកម្ពុជាធ្វើដំណើរទៅអាមេរិកហើយប្រព្រឹត្តបទល្មើស គឺអាចទទួលតាមករណីនីមួយៗ ដើម្បីសម្រេចទទួល ឬ មិនទទួល ។ នៅថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០០០ ក្រសួងការបរទេសបានជួបប្រជុំជាមួយសហរដ្ឋអាមេរិក ដោយក្រសួងការបរទេសបានឯកភាពដោះស្រាយជាគោលការណ៍តាមករណីនីមួយៗ ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ហើយកម្ពុជា និងអាមេរិកបានឯកភាព និងចេញសេចក្តីថ្លែងការណ៍រួមដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

- ទទួលបុគ្គល ដែលមិនទទួលយកសញ្ជាតិមួយទៀត
- ប្រទេសទទួលមានសិទ្ធិសម្រេចទទួល ឬ មិនទទួល
- ទទួលបុគ្គលដែលស្នើឲ្យធ្វើមាតុភូមិនិវត្តន៍
- ប្រទេសស្នើសុំត្រូវទទួលយកវិញនូវបុគ្គលដែលរកឃើញថាមិនមែនជាជនជាតិនៃប្រទេសទទួល ។

រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ទទួលយកភារៈជនត្រឡប់មកវិញ តាមគោលការណ៍នៃការពិនិត្យលើករណីនីមួយៗ ដោយឲ្យអាមេរិកធ្វើបញ្ជីឈ្មោះនិងប្រវត្តិរូបរបស់ភារៈជនឲ្យបានច្បាស់លាស់ ។ ប្រទេសទាំងពីរបានឯកភាពបង្កើតគណៈកម្មការរួមមួយ ដើម្បីដោះស្រាយបញ្ហាមាតុភូមិនិវត្តន៍ ហើយបញ្ហាងាយៗត្រូវដោះស្រាយដោយផ្អែកអន្តោប្រវេសន៍នៃប្រទេសទាំងពីរ ។

**៣. របាយការណ៍ស្តីពីការអនុវត្តរបស់ក្រុមការងារទទួលជនមាតុភូមិនិវត្តន៍**

(ដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **សុខ ផល** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍)

ក្រោយពីបានចុះកិច្ចព្រមព្រៀងរួចមក រាជរដ្ឋាភិបាលបានសម្រេចបង្កើត គណៈកម្មការទទួលមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាពីសហរដ្ឋអាមេរិក តាមរយៈនោះក្រសួងមហាផ្ទៃបានសម្រេចបង្កើតក្រុមជំនួយការទទួលជនមាតុភូមិនិវត្តន៍ផងដែរ ដែលមាននាយកដ្ឋានគ្រប់គ្រងជនបរទេសជាអ្នកអនុវត្តរហូតមក ។

**ក. លទ្ធផលនៃការអនុវត្ត**

ចាប់ពីថ្ងៃទី ២២.មីនា.២០០២ ដល់ថ្ងៃទី ១៨.ឧសភា.២០១៦ បានទទួលពលរដ្ឋអន្តោប្រវេសន៍កម្ពុជាចំនួន ២០៧លើក សរុបចំនួន ៥១២នាក់ (ស្រី ១៤នាក់) ក្នុងនោះមាន ៖

- កំពុងរស់នៅតាមមូលដ្ឋានរាជធានី-ខេត្ត ៣៤៩នាក់ (ស្រី ១៣នាក់)
- កំពុងចេញចូលស្នាក់នៅក្នុងអង្គការទ្រទ្រង់ជនមាតុភូមិនិវត្តន៍(RISE) ១០៤នាក់ (ស្រី ១នាក់)
- កំពុងអនុវត្តទោសក្នុងពន្ធនាគារ ១២នាក់ (ប្រុស)
- អនុវត្តទោសរួចចេញពីពន្ធនាគារ ២៥នាក់
- ទទួលមរណៈភាព ២២នាក់ ។

ក្នុងឆ្នាំ២០១៦ នេះ មានសំណូមពរឲ្យទទួលយកជនអន្តោប្រវេសន៍ចំនួន ៣៤នាក់ ។

ខ. ការសម្ភាស

ការសម្ភាសធ្វើឡើងដោយបើកចំហ តែមិនធ្វើការសម្ភាសចំពោះជនដែល មិនមែនជាខ្មែរពិតប្រាកដ ឬជាអ្នកជំងឺធ្ងន់ធ្ងរឡើយ ។

គ. ការឧបត្ថម្ភរបស់សហរដ្ឋអាមេរិកចំពោះជនមាតុភូមិនិវត្តន៍

- ឯកសារធ្វើដំណើរ ១០០$
- ស្រាវជ្រាវរកស្រុកកំណើត ១២៥$
- ធ្វើដំណើរទៅទីតាំងថ្មី ៧៥$
- វិភាគទានសម្រាប់ធ្វើមាតុភូមិនិវត្តន៍ ៦៥០$ (ផ្តល់តាមរយៈអង្គការក្រៅរដ្ឋាភិបាល) ។

ឃ. ផលវិបាក

ភាគច្រើននៃអ្នករស់ ឬកើតនៅទីនោះ មិនចេះភាសាខ្មែរ និងមិនយល់ដឹងពីវប្បធម៌ខ្មែរ ដូចនេះពេលមកដល់ គួរត្រូវបើកវគ្គបង្ហាត់បង្រៀនមុនបញ្ជូនទៅកាន់មូលដ្ឋាន ។

## ៤. មតិចូលរួមពីក្រសួងការបរទេស

(ដោយ ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស)

បញ្ហានេះបានកើតមានតាំងពីមុនឆ្នាំ២០០២មកម្ល៉េះ ហើយពលរដ្ឋ និងសមាគមន៍ខ្មែរនៅសហរដ្ឋអាមេរិក បានលើកឡើងអំពីបញ្ហានៃការធ្វើមាតុភូមិនិវត្តន៍នេះដែលមានដូចជា៖

- វាជាការពង្រាត់ឲ្យព្រាត់ប្រាស់គ្រួសារ (ប្តីអ្នករកចំណូល ចាប់ប្តីមកនាំឲ្យប្រពន្ធកូនវេទនា)
- អ្នកខ្លះអនុវត្តទោស និងកែប្រែរួចហើយ នៅតែចាប់បញ្ជូនមកទៀត
- អ្នកខ្លះកើតនៅទីនោះមិនចេះភាសា និងមិនយល់ដឹងពីវប្បធម៌ប្រពៃណីខ្មែរ ក៏ចាប់បញ្ជូនមកដែរ ។

ក្រសួងមហាផ្ទៃ និងក្រសួងការបរទេសធ្លាប់បានជួបពិភាក្សាអំពីបញ្ហានេះ ដោយបានលើកឡើងនូវជនដែលមិនត្រូវទទួលយក រួមមានដូចខាងក្រោម៖

- អ្នកកើតនៅអាមេរិក ត្រូវមានសញ្ជាតិអាមេរិក (ទីកន្លែងកំណើត គួរដាក់ជាល័ក្ខខ័ណ្ឌ) ។
- អ្នកដែលរស់នៅសហរដ្ឋអាមេរិកលើសពី ២០ឆ្នាំ ។
- អ្នកដែលមានគ្រួសារសាច់ញាតិនៅអាមេរិក តែមិនមាននៅកម្ពុជាសោះ (យើងបានរកឃើញក្នុងចំណោមជនដែលបានបញ្ជូនមក មានមួយចំនួនមិនមានគ្រួសារសាច់ញាតិនៅកម្ពុជាទេ) ។
- អ្នកមានជំងឺរ៉ាំរ៉ៃ ចាស់ជរា ពិការ ។
- អ្នកដែលបានអនុវត្តទោស និងកែប្រែរួចហើយក្រោយពីចេញពីពន្ធនាគារ ។
- ជនភៀសខ្លួន (ជនភៀសខ្លួន គឺភៀសខ្លួនដោយសារមិនចង់រស់នៅប្រទេសដើម តាមច្បាប់ HCR ជនភៀសខ្លួនមិនត្រូវបញ្ជូនទៅប្រទេសដើមវិញទេ) ។

តែយើងទទួលយកអ្នកដែលរស់នៅហួសកាលកំណត់ទិដ្ឋាការ ដូចជាអ្នកទេសចរណ៍ ឬ អ្នកទៅសួរសុខទុក្ខគ្រួសារជាដើម ។

ជំហររបស់ក្រសួងការបរទេស គឺនៅតែទទួលយក (ទទួលយកក្នុងល័ក្ខខ័ណ្ឌមួយ) ដោយស្នើសុំឲ្យធ្វើវិសោធនកម្មអនុស្សរណៈ ។

## ៥. សរុបមតិ និងអនុសាសន៍របស់ **សម្តេចក្រឡាហោម**

- ការទទួលជនមាតុភូមិនិវត្តន៍កម្ពុជាគឺខាងអន្តោប្រវេសន៍ជាអ្នកទទួល រួចធ្វើការបែងចែកដោយសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីរៀបចំចាត់បញ្ជូនទៅតាមរាជធានី-ខេត្ត ។

• កម្ពុជាមានគោលជំហរទទួលយកជនអន្តោប្រវេសន៍ដដែល តែត្រូវមានការកែសម្រួលមួយចំនួនដូចជា៖
- កំណត់ឆ្នាំ (ឪពុកម្តាយជាអន្តោប្រវេសន៍ខុសច្បាប់នៅអាមេរិក តែកូនកើតនៅទីនោះ រស់នៅទីនោះ មិនចេះនិយាយភាសាខ្មែរ ដូចនេះគួរតែមានការកំណត់ឆ្នាំពីរយៈពេលចេញពីប្រទេស និងរយៈពេលរស់នៅទីនោះ) ។
- កំណត់ឋានៈជនភៀសខ្លួន (អ្នកទៅមុនឆ្នាំ១៩៩៣ គ្មានលទ្ធភាពទៅអាមេរិកទេ តែអាមេរិកជាអ្នកទទួលយកទៅ ហើយអ្នកខ្លះបានGreenCard ដូចនេះមិនមែនជាអន្តោប្រវេសន៍ខុសច្បាប់ទេ មិនត្រូវបញ្ជូនត្រឡប់មកវិញឡើយ) ។
- ឈរលើគោលការណ៍ស្ម័គ្រចិត្តដោយមិនបង្ខិតបង្ខំ (បន្ថែមនៅក្នុងចំណុចទី១ នៃអនុស្សរណៈ) ។

• ជាចុងក្រោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានដឹកនាំអង្គពិភាក្សាបានឯកភាពស្នើសុំបង្កើតគណៈកម្មការមួយ សម្រាប់ធ្វើការកែសម្រួល និងព្រាងខ្លឹមសារនៃអនុស្សរណៈឡើងវិញ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលសម្រេច ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម | **ឡុង វិសាលោ** | ប្រធាន |
| - ឯកឧត្តម នាយឧត្តមសេនីយ៍ | **អ៊ុក គឹមលេខ** | អនុប្រធាន |
| - លោកជំទាវ | **ជូ ប៊ុនអេង** | អនុប្រធាន |
| - ឯកឧត្តម | **សៀង ឡាប្រេស្ស** | សមាជិក |
| - ឯកឧត្តម នាយឧត្តមសេនីយ៍ | **សុខ ផល** | សមាជិក |
| - ឯកឧត្តម | **កែវ វិសិដ្ឋ** | សមាជិក |
| - ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ប៉ោ ភក្តិ** | សមាជិក |
| - លោកឧត្តមសេនីយ៍ទោ | **ផាត សុផានិត** | សមាជិក |

កិច្ចប្រជុំបានប្រព្រឹត្តទៅយ៉ាងផុលផុស និងដោយរលូន ហើយបានបញ្ចប់នៅ វេលាម៉ោងដប់ប្រាំមួយ និងប្រាំនាទីរសៀល ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦
**អ្នកកត់ត្រា**

ឧត្តមសេនីយ៍ត្រី **គង់ ពុទ្ធី**

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

# សមាសភាពចូលរួមកិច្ចប្រជុំ
## ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការ របស់គណៈកម្មការរួម កម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍

## ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦
## នៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគារ "A"

| | | | |
|---|---|---|---|
| - សម្តេចក្រឡាហោម | ស ខេង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | |
| - ឯកឧត្តម | ឡុង វិសាលោ | រដ្ឋលេខាធិការ | ក្រសួងការបរទេស |
| - ឯកឧត្តម | កែវ វិសិដ្ឋ | ប្រធាននាយកដ្ឋាន | ក្រសួងការបរទេស |
| - ឯកឧត្តម | សៀង ឡាប្រេស្ស | ទីប្រឹក្សារាជរដ្ឋាភិបាល | |
| - ឯកឧត្តម | សក់ សេដ្ឋា | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - ឯកឧត្តម | ឯម សំអាន | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - ឯកឧត្តម នាយឧ. | អ៊ុក គឹមលេខ | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - ឯកឧត្តម | ងី ច័ន្ទ្រផល | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - ឯកឧត្តម ឧ.ឯក | ប៉ោ ភក្តិ | អគ្គលេខាធិការរង | ក្រសួងមហាផ្ទៃ |
| - ឧត្តមសេនីយ៍ទោ | ផាត សុផានិត | នាយករងខុទ្ទកាល័យ | ក្រសួងមហាផ្ទៃ |
| - លោក | ជូ ច័ន្ទដារ៉ា | ជំនួយការ | ឯកឧត្តម នាយឧ.អ៊ុក គឹមលេខ |
| - ឯកឧត្តម នាយឧ. | សុខ ផល | អគ្គនាយក | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| - ឯកឧត្តម នាយឧ. | ផៃ ស៊ីផាន់ វិទ្ធ | អគ្គស្នងការរង | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| - លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្តីទី | គ.ជ.ប.ជ |
| - វរៈសេនីយ៍ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - វរៈសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| - លោក | អ៊ុំ កាមិន្ទ | នាយការិយាល័យ | គ.ជ.ប.ជ |
| - អនុសេនីយ៍ឯក | ស្រី មករា | នាយរងការិយាល័យ | គ.ជ.ប.ជ |
| - អនុសេនីយ៍ឯក | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| - អនុសេនីយ៍ទោ | សៅ ស៊ីនួន | នាយផ្នែក | គ.ជ.ប.ជ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៤៥៦ នស

រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦

# ដីកាបញ្ជូន

## គោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

| ល.រ | ខ្លឹមសារលិខិត | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|
| | | ច្បាប់ | ទំព័រ | |
| ០១ | សំណើសុំបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីសិក្សាលើខ្លឹមសារសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជា ដើម្បីកែសម្រួល និងព្រាងខ្លឹមសារជាថ្មី ។ | ០១ | ០២ | " ដើម្បីជូនជាសមត្ថកិច្ច " |
| ០២ | កំណត់ហេតុនៃកិច្ចប្រជុំ ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការរបស់គណៈកម្មការរួម កម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ។ | ០១ | ០៤ | |

ជ.រដ្ឋមន្ត្រី
អនុរដ្ឋលេខាធិការ

ឧត្តមសេនីយ៍ឯក. ប៉ៀ-ភក្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ:.........................

រាជធានីភ្នំពេញ,ថ្ងៃទី ខែសីហា ឆ្នាំ២០១៦

# ដីកាបញ្ជូន

## គោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

| ល.រ | ខ្លឹមសារលិខិត | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|
| | | ច្បាប់ | ទំព័រ | |
| ០១ | សំណើសុំបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីសិក្សាលើខ្លឹមសារ សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជា ដើម្បីកែសម្រួល និងព្រាងខ្លឹមសារជាថ្មី ។ | ០១ | ០២ | " ដើម្បីជូនជាសមត្ថកិច្ច " |
| ០២ | កំណត់ហេតុនៃកិច្ចប្រជុំ ស្តីពីការកែសម្រួលអនុស្សរណៈរវាង រាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការរបស់គណៈកម្មការរួម កម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ។ | ០១ | ០៤ | |

ស.រ.រដ្ឋមន្ត្រី
អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក.ជៅ-ភក្តី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ:១៤៤៤ សជណ

# សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុៈ** សំណើសុំបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីសិក្សាលើខ្លឹមសារសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជា ដើម្បីកែសម្រួល និងព្រាងខ្លឹមសារជាថ្មី ។

**យោងៈ** ស្មារតីនៃកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការពិភាក្សាលើខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជា ដែលកំពុងមានបញ្ហាប្រឈមត្រូវដោះស្រាយ ។

សេចក្តីដូចបានគោរពជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា កាលពីឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិកបានចុះអនុស្សរណៈ ស្តីអំពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាដែលរត់គេចពីសង្គ្រាមកាលពីបួនទសវត្សរ៍មុនទៅរស់នៅសហរដ្ឋអាមេរិក ហើយបានប្រព្រឹត្តបទល្មើស។ ឆ្លងតាមការអនុវត្តកន្លងមកឃើញថា អនុស្សរណៈនេះគួរត្រូវធ្វើការកែសម្រួលខ្លឹមសារចាំបាច់មួយចំនួនឱ្យស្របតាមបរិបទបច្ចុប្បន្ន ជាពិសេសលើបញ្ហាសុខុមាលភាព និងគោលការណ៍គោរពសិទ្ធិមនុស្សជាអន្តរជាតិ។ ដើម្បីដំណើរការពិនិត្យលើអនុស្សរណៈនេះ ខ្ញុំសូមគោរពស្នើសុំ **សម្តេច** បង្កើតក្រុមការងារចំពោះកិច្ចមួយ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | **ប្រធាន** |
| ២. ឯកឧត្តមនាយឧត្តមសេនីយ៍ | **អ៊ុក គឹមលេខ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារអន្តោប្រវេសន៍ | **អនុប្រធាន** |
| ៣. លោកជំទាវ | **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | **អនុប្រធាន** |
| ៤. ឯកឧត្តម | **សៀង ឡាប្រេស្ស** | ទីប្រឹក្សារាជរដ្ឋាភិបាល | **សមាជិក** |
| ៥. ឯកឧត្តមនាយឧត្តមសេនីយ៍ | **សុខ ផល** | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | **សមាជិក** |
| ៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ប៉ោ ភក្តិ** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | **សមាជិក** |

៧. លោកឧត្តមសេនីយ៍ទោ **ផាត សុផានិត** ជំនួយការសម្តេចក្រឡាហោម **សមាជិក**

៨. លោក **ចូ សំណាង** អនុប្រធាននាយកដ្ឋានច្បាប់កុងស៊ុលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយសេចក្តីអនុគ្រោះ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

11-8-16

15/08/16